00528371

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 09 / 06 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

លេខ/No: D345/5/11

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពីការបង្កើតឲ្យ
មានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម
ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

| | |
|---|---|
| សំណុំរឿងលេខ: | ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ៦០) |
| ចំពោះមុខ៖ | ចៅក្រម ប្រាក់ គឹមសាន ប្រធាន |
| | ចៅក្រម Rowan DOWNING |
| | ចៅក្រម ន៉ីយ ធុល |
| | ចៅក្រម Catherine MARCHI-UHEL |
| | ចៅក្រម ហួត វុទ្ធី |
| កាលបរិច្ឆេទ៖ | ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១០ |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 09 / 06 / 2010
ម៉ោង (Time/Heure): 10:15
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

## សាធារណៈ

## សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចលើសំណើរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ជនត្រូវចោទ**

លោក អៀង សារី

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

លោក ន៊ី ច័ន្ទឌី

លោក Mahdev MOHAN

**សហមេធាវីការពារជនត្រូវចោទ**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C.

---

កញ្ញា Lima NGUYEN
លោក គីម ម៉េងឃី
លោកស្រី ម៉ុច សុវណ្ណារី
លោកស្រី Elizabeth-Joelle RABESANRATANA
លោកស្រី Annie DELAHAIE
លោក Philippe CANONNE
លោកស្រី Martine JACQUIN
លោកស្រី Fabienne TRUSSES-NAPROUS
លោកស្រី Françoise GAUTRY
លោកស្រី Isabelle DURAND
លោកស្រី Christine MARTINEAU
លោកស្រី Laure DESFORGES
លោក Ferdinand DJAMMEN
លោក ឡោ ជុនធី
លោកស្រី ស៊ីន សុវន
លោក សំ សុគង់
លោក ហុង គីមសួន
លោក គង់ ពិសី
លោក គង់ ហេង
លោកស្រី Silke STUDZINSKY
លោក Olivier BAHOUGNE
លោកស្រី Marie GUIRAUD
លោក Partirck BAUDOUIN
លោកស្រី ជេត វណ្ណលី
លោក ពេជ អង្គ
លោក Julien RIVET
លោក Pascal AUBOIN

**ដើមបណ្ដឹងរដ្ឋប្បវេណីគ្មានអ្នកតំណាង**

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C.

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក ") បានទទួល "បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចលើសំណើរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ" ដែលសហមេធាវីការពារក្តីរបស់ជនត្រូវចោទ អៀង សារី បានដាក់ជូនកាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១០ ("បណ្តឹងឧទ្ធរណ៍")[១]។

## I. សេចក្តីផ្តើម

១. កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១០ សហមេធាវីការពារក្តីរបស់លោក អៀង សារី បានដាក់ "សំណើរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ" ("សំណើ")[២] និង "សំណើជាជម្រើសមួយទៀតរបស់លោក អៀង សារី ស្តីពីការកម្រិតព្រំដែននៃការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើនៅ អវតក ("សំណើជាជម្រើស")[៣]។ សហមេធាវីការពារក្តីបានស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេត "បដិសេធចោលនូវការអនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើនៅចំពោះមុខ អ.វ.ត.ក" ឬ ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេតយល់ឃើញថា ទ្រឹស្តីនេះអាចយកមកអនុវត្តបាននោះ សហចៅក្រមស៊ើបអង្កេតគួរតែ៖ "ក) បដិសេធការអនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ៣ ថ្មី នៃច្បាប់បង្កើត អ.វ.ត.ក ខ) អនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ចំពោះតែស្ថានភាពទាំងឡាយណាដែលពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធអន្តរជាតិតែប៉ុណ្ណោះ គ) អនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ តែក្នុងករណីដែលមានទំនាក់ទំនងទៅវិញទៅមក រវាងសកម្មភាពរបស់ថ្នាក់លើជាមួយនឹងបទល្មើសរបស់កូនចៅរបស់ខ្លួន និងក្នុងករណីដែលបទល្មើសទាំងនោះពាក់ព័ន្ធ

---

[១] បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់ កសចស សម្រេចលើសំណើរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១០ ឯកសារលេខ D345/5/1។

[២] សំណើរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើនៅ អវតក ចុះថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១០ ឯកសារលេខ D345/2។

[៣] សំណើជាជម្រើសរបស់លោក អៀង សារី ស្តីពីព្រំដែនកម្រិតនៃការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើនៅ អវតក ចុះថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១០ ឯកសារលេខ D345/3។

ជាមួយ នឹងសកម្មភាពទាំងឡាយ ដែលថ្នាក់លើមានកាតព្វកិច្ចតាមផ្លូវច្បាប់ជាមុនរួចស្រេច ដើម្បីទប់ស្កាត់ ឬដាក់ទណ្ឌកម្ម និង ឃ) បដិសេធការអនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើចំពោះបទល្មើសដែលមានចេតនាជាក់លាក់មួយចំនួន ដូចជា អំពើប្រល័យពូជសាសន៍"។

២. នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចលើសំណើរបស់ អៀង សារី ប្រឆាំងនឹងការអនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ("ដីកាសម្រេច")[៤]។ សហចៅក្រមស៊ើបអង្កេតបានសម្រេចមិនពិចារណាទៅលើសំណើនេះទេ ដោយសារសហចៅក្រមស៊ើបអង្កេតបានពិចារណាឃើញថា សំណើនេះគឺពិតជា "សំណើសុំឱ្យបកស្រាយច្បាប់"[៥]។ សហចៅក្រមស៊ើបអង្កេត "មិនបានពិចារណាទៅលើសំណើជាជម្រើស" នេះទេ ដោយសារសហចៅក្រមស៊ើបអង្កេតបានយល់ឃើញថា នេះគឺជា "ការដាក់សំណើដដែលលើបញ្ហាតែមួយ" "ដោយមិនគោរពទាល់តែសោះ" ទៅនឹងសេចក្តីបង្គាប់របស់ខ្លួន ទៅនឹងសំណើរបស់សហមេធាវីការពារក្តីសុំឱ្យបន្ថែមចំនួនទំព័រ ដែលបានកំណត់សម្រាប់សំណើសុំនេះ[៦]។ សហចៅក្រមស៊ើបអង្កេតបានលើកឡើងនៅក្នុងដីកាសម្រេចនេះថា សហចៅក្រមស៊ើបអង្កេតនឹងដោះស្រាយបញ្ហាអង្គច្បាប់ដែលទាក់ទងនឹងការទទួលខុសត្រូវរបស់ថ្នាក់លើ នៅក្នុងដីកាដំណោះស្រាយ ប្រសិនបើចាំបាច់[៧]។

៣. នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១០ សហមេធាវីការពារក្តីរបស់ជនត្រូវចោទបានដាក់ការជូនដំណឹងអំពីការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចនេះ ហើយនៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១០ សហមេធាវីការពារក្តីបានដាក់បណ្តឹងឧទ្ធរណ៍នេះ។ នៅក្នុងបណ្តឹងឧទ្ធរណ៍នេះ សហមេធាវីការពារក្តីស្នើសុំឱ្យអង្គបុរេជំនុំជម្រះ ក) ប្រកាសថា បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន ដោយអនុលោមតាមវិធាន ៧៣(៣)(ក) និងវិធាន ២១ នៃវិធានផ្ទៃក្នុង ខ) ច្រានចោលការបដិសេធរបស់ ក.ស.ច.ស មិនទទួលយកសំណើទាំងពីរ និង គ) ប្រកាសថា ការទទួលខុសត្រូវរបស់ថ្នាក់លើមិនអាចយកមកអនុវត្តនៅ អ.វ.ត.ក បានទេ។

---

[៤] ចេញដីកាសម្រេចលើសំណើរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១០ ឯកសារលេខ D345/4។

[៥] កថាខណ្ឌ ១០ ដល់ ១៣ នៃដីកាសម្រេច។

[៦] កថាខណ្ឌ ៦ ដល់ ៩ នៃដីកាសម្រេច។

[៧] កថាខណ្ឌ ១២ នៃដីកាសម្រេច។

00528375



៤. នៅថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១០ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍នេះ ("ចម្លើយតបរបស់សហព្រះរាជអាជ្ញា")[៨]។ សហព្រះរាជអាជ្ញាស្នើសុំឱ្យអង្គបុរេជំនុំជម្រះប្រកាសថា បណ្តឹងឧទ្ធរណ៍នេះមិនទទួលយកទេ ឬ ប្រសិនបើអង្គបុរេជំនុំជម្រះយល់ឃើញថា បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបានវិញនោះ អង្គបុរេជំនុំជម្រះគួរតែបដិសេធបណ្តឹងឧទ្ធរណ៍នេះចោល ដោយតម្កល់ទុកដីកាសម្រេចនេះនៅដដែល និងប្រកាសថា ការទទួលខុសត្រូវរបស់ថ្នាក់លើអាចយកមកអនុវត្តនៅ អ.វ.ត.ក បាន[៩]។

៥. នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះបានកំណត់កាលបរិច្ឆេទបើក*សវនាការជាសម្ងាត់* នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១០ នៅវេលាម៉ោង ៩.០០ ព្រឹក ដើម្បីសម្រេចអំពីបណ្តឹងឧទ្ធរណ៍នេះ។ នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១០ សហព្រះរាជអាជ្ញាបានជូនដំណឹងមកអង្គបុរេជំនុំជម្រះថា ខ្លួនមិនមានបំណងចូលរួមក្នុងសវនាការសួរដេញដោយផ្ទាល់មាត់អំពីបណ្តឹងឧទ្ធរណ៍នេះទេ[១០]។ នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១០ ដដែលនេះ សហមេធាវីរបស់ជនត្រូវចោទបានដាក់ការឆ្លើយតបជាលាយលក្ខណ៍អក្សរ[១១] ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា "ដែលបានព្រាងរៀបចំឡើងដើម្បីគាំទ្រដល់សេចក្តីសន្និដ្ឋានជាលក្ខណ៍អក្សររបស់ខ្លួន ជំនួសឱ្យការដេញដោលដោយផ្ទាល់មាត់ ("ការឆ្លើយតប")។ សហមេធាវីការពារក្តីបានបញ្ជាក់ថា ប្រសិនបើអង្គបុរេជំនុំជម្រះយល់ឃើញថា ការឆ្លើយតបផ្ទាល់មាត់មិនចាំបាច់ទេនោះ ហើយការឆ្លើយតបជាលាយលក្ខណ៍អក្សរគឺជាការគ្រប់គ្រាន់នោះ ពួកគាត់មិនជំទាស់នឹងការលុបចោលសវនាការនេះទេ"[១២]។ នៅថ្ងៃទី២៦ ខែឧសភា

---

[៨] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើ ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១០ ឯកសារ D345/5/2។

[៩] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦២ ដល់ ៦៣។

[១០] ការដកមកវិញនូវសេចក្តីជូនដំណឹងអំពីការចូលរួមរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១០ ឯកសារលេខ D345/5/8។

[១១] ការឆ្លើយតបជាលាយលក្ខណ៍អក្សររបស់លោក អៀង សារី គាំទ្រដល់សេចក្តីសន្និដ្ឋានផ្ទាល់មាត់ សម្រាប់សវនាការនៅចំពោះមុខអង្គបុរេជំនុំជម្រះ ទាក់ទងនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការទទួលខុសត្រូវរបស់ថ្នាក់លើ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១០ ឯកសារលេខ D345/5/9។

[១២] អ៊ីមែល ចុះថ្ងៃទី ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១០ ដែលទីប្រឹក្សាច្បាប់របស់ក្រុមមេធាវីការពារក្តី អៀង សារី បានផ្ញើជូនមកក្រឡាបញ្ជីរបស់អង្គបុរេជំនុំជម្រះ។



E.C.C.C * C.E.T.C PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

00528376



ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះបានសម្រេចលុបចោលសវនាការលើបណ្តឹងឧទ្ធរណ៍នេះ[១៣]។

៦. នៅក្នុងការឆ្លើយតបរបស់ខ្លួនទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា សហមេធាវីការពារក្តីរបស់ជនត្រូវចោទស្នើសុំឱ្យអង្គបុរេជំនុំជម្រះទទួលយកបណ្តឹងឧទ្ធរណ៍ និងសំណូមពរដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍នេះ។

## II. ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

៧. ដីកាសម្រេចត្រូវបានធ្វើឡើង និងជូនដំណឹងដល់ភាគីទាំងអស់នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១០។ សហមេធាវីការពារក្តីរបស់ជនត្រូវចោទ បានដាក់ការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍របស់ខ្លួននៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១០។ បណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ជូននៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១០ ពោល គឺស្ថិតនៅក្នុងអំឡុងពេលដែលបានកំណត់ក្នុងវិធាន ៧៥(៣) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក (“វិធានផ្ទៃក្នុង”)។

៨. ដោយទទួលស្គាល់ថា ដីកាសម្រេចនេះ“មិនបញ្ជាក់ឱ្យបានច្បាស់លាស់អំពីយុត្តាធិការរបស់ អ.វ.ត.ក ចំពោះការអនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ” សហមេធាវីការពារក្តីលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍ថា វិធាន ៧៤(៣)(ក) ផ្តល់សិទ្ធិឱ្យប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា ដោយបញ្ជាក់ពីយុត្តាធិការរបស់ អ.វ.ត.ក។ បន្ថែមលើនេះទៀត ដោយយោងទៅកថាខណ្ឌ ១២ នៃដីកាសម្រេច សហមេធាវីការពារក្តីយល់ឃើញថា ការបដិសេធរបស់សហចៅក្រមស៊ើបអង្កេតមិនព្រមដោះស្រាយសំណើសុំនានា នៅក្នុងដំណាក់កាលនេះបណ្តាលឱ្យមានការបដិសេធតាមការសន្មតលើសំណើដែលបានស្នើសុំ ហើយដោយយោងទៅលើយុត្តិសាស្ត្រមុនៗរបស់អង្គបុរេជំនុំជម្រះ[១៤] សហមេធាវីការពារក្តីស្នើសុំឱ្យអង្គបុរេជំនុំជម្រះទទួលយកបណ្តឹងឧទ្ធរណ៍នេះ ដោយសារតែមូលហេតុនៃការបដិសេធតាមការសន្មតនេះ។ សហមេធាវីការពារក្តីក៏បានលើកឡើងផងដែរថា បណ្តឹងឧទ្ធរណ៍អាចទទួលយកបាននៅក្រោមវិធាន ២១ នៃវិធានផ្ទៃក្នុង ដែលបញ្ជាក់អះអាងថា ការខកខានរបស់សហចៅក្រមស៊ើបអង្កេត មិនបានដោះស្រាយការជំទាស់តវ៉ាអំពី

[១៣] ដីកាសម្រេចលុបចោលសវនាការ ចុះថ្ងៃទី ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១០ ឯកសារលេខ D345/5/10 ។

[១៤] កថាខណ្ឌ ១ នៃបណ្តឹងឧទ្ធរណ៍ ។

អង្គជំនុំជម្រះ ... PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

យុត្តាធិការ គឺរំលោភទៅលើសិទ្ធិរបស់ជនត្រូវចោទក្នុងការមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ ដើម្បីត្រៀមរៀបចំការពារខ្លួន[១៥]។

៩. នៅក្នុងចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាលើកឡើងថា បណ្តឹងឧទ្ធរណ៍នេះ "មិនមានចែងក្នុងវិធាន ៧៤(៣) នៃវិធានផ្ទៃក្នុងនោះទេ ហើយបើដូច្នេះ [បណ្តឹងឧទ្ធរណ៍]មិនលើកនូវបញ្ហាដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិជាមូលដ្ឋានរបស់ដើមបណ្តឹងឧទ្ធរណ៍ អំពីការទទួលបាននូវការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌"[១៦] នោះទេ។ សហព្រះរាជអាជ្ញាជំទាស់តវ៉ាថា "កម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍នេះ គឺពិតជាសំណើបកស្រាយច្បាប់" ហើយ "ក្រុមខ័ណ្ឌនីតិវិធីរបស់ អ.វ.ត.ក មិនតម្រូវឱ្យសហចៅក្រមស៊ើបអង្កេតចេញដីកាបកស្រាយច្បាប់ទេ ហើយស្របជាមួយគ្នានេះដែរ ក្រុមខ័ណ្ឌនីតិវិធីក៏មិនបានចែងពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបកស្រាយច្បាប់ ដែលអាចចេញដោយសហចៅក្រមស៊ើបអង្កេតនោះដែរ"[១៧]។ សហព្រះរាជអាជ្ញាលើកឡើងថា បណ្តឹងឧទ្ធរណ៍នេះមិនស្ថិតក្នុងមូលហេតុនៃការប្តឹងឧទ្ធរណ៍ ដូចដែលមានចែងក្នុងវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុងនោះទេ ពីព្រោះត្រឹមតែសេចក្តីសម្រេចមួយទៅលើភាពអាចរកបាននៃទម្រង់ទទួលខុសត្រូវ វាមិនស្មើនឹង "ការបញ្ជាក់អះអាងទៅលើយុត្តាធិការរបស់តុលាការបាននោះទេ"[១៨]។ សហព្រះរាជអាជ្ញាក៏បានជំទាស់តវ៉ាផងដែរថា វិធាន ២១ នៃវិធានផ្ទៃក្នុង មិនតម្រូវឱ្យអង្គបុរេជំនុំជម្រះសម្រេចធ្វើការបកស្រាយឱ្យបានទូលំទូលាយអំពីសិទ្ធិរបស់ជនត្រូវចោទក្នុងការប្តឹងឧទ្ធរណ៍ ដែលស្ថិតនៅក្រោមមាត្រា ៧៤(៣)(ក) នោះទេ ដោយសារសិទ្ធិរបស់ជនត្រូវចោទត្រូវបានរក្សាទុកលទ្ធភាពដើម្បីធ្វើសារណាបែបនេះ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល[១៩]។

១០. ក្នុងការឆ្លើយតបរបស់ខ្លួន សហមេធាវីការពារក្តីរបស់ជនត្រូវចោទទទូចស្នើសុំថា ការបដិសេធរបស់សហចៅក្រមស៊ើបអង្កេតមិនសម្រេចទៅលើសំណើសុំនានារបស់ខ្លួន គឺបណ្តាលឱ្យមានការ

---

[១៥] កថាខណ្ឌ ២ និង ៣ នៃបណ្តឹងឧទ្ធរណ៍ ។

[១៦] កថាខណ្ឌ ៥ នៃចម្លើយតបរបស់សហព្រះរាជអាជ្ញា។

[១៧] កថាខណ្ឌ ៦ នៃចម្លើយតបរបស់សហព្រះរាជអាជ្ញា។

[១៨] កថាខណ្ឌ ៧ នៃចម្លើយតបរបស់សហព្រះរាជអាជ្ញា។

[១៩] កថាខណ្ឌ ៨ នៃចម្លើយតបរបស់សហព្រះរាជអាជ្ញា។

បដិសេធសំណើសុំតាមការសន្មត ហើយ "ហេតុដូច្នេះ វាបញ្ជាក់ពីយុត្តាធិការរបស់ អ.វ.ត.ក"។ សហមេធាវីការពារក្តីពន្យល់ថា បណ្តឹងឧទ្ធរណ៍នេះមិនបានស្នើសុំឱ្យមានការបកស្រាយច្បាប់នោះទេ ហើយលើកឡើងម្តងហើយម្តងទៀតថា បណ្តឹងឧទ្ធរណ៍នេះ "អាចទទួលយកបាន អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង ដោយសារបញ្ហាអង្គច្បាប់ដែលបានលើកឡើងធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ជនត្រូវចោទក្នុងការមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំការពារខ្លួន"[២០]។

១១. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា តាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុងចែងថា៖

> "ជនត្រូវចោទ ឬជនជាប់ចោទ អាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា ឬសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដូចខាងក្រោម៖
>
> ក) ការបញ្ជាក់ពីយុត្តាធិការរបស់ អវតក"។

ដូចដែលសហមេធាវីការពារក្តីបានទទួលស្គាល់នៅក្នុងបណ្តឹងឧទ្ធរណ៍ផងដែរ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា បណ្តឹងឧទ្ធរណ៍នេះពាក់ព័ន្ធទៅនឹងដីកាសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែល "មិនធ្វើការសម្រេចសេចក្តី" គឺមិនមែនចំពោះការបញ្ជាក់ពីយុត្តាធិការរបស់ អ.វ.ត.ក នោះទេ។ សហមេធាវីការពារក្តីបញ្ជាក់ថា ការបដិសេធរបស់សហចៅក្រមស៊ើបអង្កេតមិនព្រមដោះស្រាយសំណើសុំនានា នៅក្នុងដំណាក់កាលនេះ បណ្តាលឱ្យមានការបដិសេធតាមការសន្មតលើសំណើដែលបានស្នើសុំ និងស្នើសុំឱ្យអង្គបុរេជំនុំជម្រះទទួលយកបណ្តឹងឧទ្ធរណ៍នេះ ដោយសារតែមូលហេតុនៃការបដិសេធតាមការសន្មត។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានលើកឡើងថា "សហចៅក្រមស៊ើបអង្កេតនឹងយកចិត្តទុកដាក់ចំពោះបញ្ហាអង្គច្បាប់ទាក់ទងទៅនឹងការទទួលខុសត្រូវរបស់ថ្នាក់លើ នៅពេលរៀបចំសេចក្តីព្រាងដីកាដំណោះស្រាយ ប្រសិនបើចាំបាច់"[២១]។ ក្នុងន័យនេះ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា វិធានផ្ទៃក្នុងមិនចងកាតព្វកិច្ចសហចៅក្រមស៊ើបអង្កេតឱ្យសម្រេចបញ្ហានេះ នៅមុនពេលចេញដីកាដំណោះស្រាយនោះទេ។ ប៉ុន្តែ នៅក្នុងដំណាក់កាលនេះនៃដំណើរការនីតិវិធី ការចេញដីកាដំណោះស្រាយជិតនឹងមកដល់ហើយ ហើយប្រសិនបើ ដីកាដំណោះស្រាយបញ្ជាក់ពីយុត្តាធិការរបស់ អ.វ.ត.ក

[២០] កថាខណ្ឌ ៤/ក ដល់ ច នៃការឆ្លើយតប។

[២១] កថាខណ្ឌ ១២ នៃដីកាសម្រេច។

ទៅលើការទទួលខុសត្រូវរបស់ថ្នាក់លើនោះ ជនត្រូវចោទអាចពិចារណាអំពីអានុភាពវិធាន ៦៧(៥) និង វិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង នៅពេលអានវិធានទាំងពីរនេះរួមគ្នា។

មកដល់ដំណាក់កាលនេះ វាមិនប្រាកដប្រជានៅឡើយថា តើសហចៅក្រមស៊ើបអង្កេតអាចមានការពិចារណាត្រឹមកម្រិតណាចំពោះយុត្តាធិការរបស់ អ.វ.ត.ក ទាក់ទងទៅនឹងការបញ្ជារបស់ថ្នាក់លើ ប្រសិនបើមាន។ សហចៅក្រមស៊ើបអង្កេតមិនជាប់កាតព្វកិច្ចក្នុងការធ្វើសេចក្តីសម្រេចបកស្រាយច្បាប់ ដូចដែលបានលើកឡើងយ៉ាងមានប្រសិទ្ធភាពនៅក្នុងសំណើសុំនេះទេ ហើយអង្គបុរេជំនុំជម្រះនឹងមិនផ្តល់គំនិតយោបល់បែបប្រឹក្សាណាមួយនោះទេ និងមិនអាចដាក់កំហិតសហចៅក្រមស៊ើបអង្កេតក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ទាក់ទងទៅនឹងសេចក្តីសម្រេចដែលត្រូវបញ្ជាក់ជូននៅក្នុងដីកាដំណោះស្រាយនោះ។

អង្គបុរេជំនុំជម្រះយល់ឃើញថា សិទ្ធិរបស់ជនត្រូវចោទមិនត្រូវបានប៉ះពាល់ ដោយការប្រកាសមិនទទួលយកបណ្តឹងឧទ្ធរណ៍ នៅក្នុងដំណាក់កាលនេះនៃដំណើរការនីតិវិធីទេ ហើយវិធាន ២១ នៃវិធានផ្ទៃក្នុងក៏មិនបានចាប់បង្ខំឲ្យអង្គបុរេជំនុំជម្រះសម្រេចទទួលយកបណ្តឹងឧទ្ធរណ៍នេះដែរ។

១២. អង្គបុរេជំនុំជម្រះយល់ឃើញថា បណ្តឹងឧទ្ធរណ៍នេះមិនអាចទទួលយកបានទេ។

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទថា ÷**

បណ្តឹងឧទ្ធរណ៍នេះគឺមិនអាចទទួលយកបាន។

ដោយអនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សាលដីកានេះបិទផ្លូវតវ៉ា។

ភ្នំពេញ ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១១

**អង្គបុរេជំនុំជម្រះ**

ប្រធាន

**Rowan DOWNING** **ន័យ ថុល** **Catherine MARCHI-UHEL** **ហួត វុទ្ធី** **ប្រាក់ គឹមសាន**